V改編自：新住民語文學習教材
□自編_

111年新北市各級學校東南亞語文競賽
團體朗讀文稿　東埔寨國高中組A-2

# ពិធីបុណ្យអុំទូក

ពិធីបុណ្យអុំទូកគឺចាប់ធ្វើនៅថ្ងៃ ១៤កើត និង ១៥កើត ដល់១ រោច ខែកក្តិត ហើយក៏ជាពិធីបុណ្យចុងក្រោយបង្អស់ក្នុងមួយឆ្នាំដែរ។
ពិធីនេះមានដើមកំណើតចាប់ផ្តើមតាំងពីសម័យអង្គររជ្ជកាលព្រះបាទជ័យវរ្ម័នទី៧មកម្លេះ។

ការប្រណាំងទូក
ធ្វើដើម្បីរម្លឹកដល់គុំរូវីរភាពដ៏អង់អាចក្លាហានរបស់កងទ័ពជើងទឹករបស់ខ្មែរដែលបានរំដោះទឹកដី អោយរួចផុតពីការជិះជាន់របស់ពួកខ្មាំងសត្រូវ។
ចាប់ផ្តើមតាំងពីសម័យអង្គររជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ដ៏រីកចម្រើនរុងរឿង។

បណ្តែតប្រទីប
គឺធ្វើដើម្បីរំឭកដល់គុណព្រះគង្គានិងព្រះធរណី
ដែលបានផ្តល់នូវសេចក្តីសុខសប្បាយភោគផងក្នុង
ការងារកសិកម្មរបរចិញ្ចឹមជីវិតដល់ប្រជាកសិករ។

ពិធីបុណ្យអុំទូកគឺចាប់ធ្វើនៅថ្ងៃ ១៤កើតនិង១៥កើត
ដល់១ រោច ខែកត្តិត ។ប្រារពធ្វើនៅទន្លេចតុមុខខាង
មុខព្រះបរមរាជវាំង ដោយមានមនុស្សម្នាយ៉ាងច្រើន
កុះករ ក្រោមពន្លឺកាំរស្មីកាំជ្រួចដ៏ស្រស់ត្រកាល ។